ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតធានាអះអាង

ឈ្មោះ **លី សៀវមិញ** ភេទ ស្រី ដែលកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១២៩៥៤១១ អាសយដ្ឋាន ភូមិគោកឃ្លាង ឃុំ/សង្កាត់ភ្នំពេញថ្មី ស្រុក/ខណ្ឌសែនសុខ រាជធានី/ខេត្តភ្នំពេញ តួនាទីជា ប្រធានរដ្ឋបាល នៅ សហគ្រាស គ្រឹះស្ថាន **ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីធីត** ពិតជាបានទទួលការណែនាំពីការរៀបចំលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ និងបញ្ជីរាយនាមកម្មកររនិយោជិត ពីមន្ត្រីឈ្មោះ **ឡូញ ង៉ែត** ភេទប្រុស ដែលមានអត្តលេខការងារ **១៨៩២១០០៥០៦** របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចខាងក្រោម៖

១-ការដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារតាមទម្រង់ដែលបានកំណត់ ទៅនាយកដ្ឋានអធិការកិច្ចការងារ ដោយភ្ជាប់មកជាមួយនូវ៖

- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- កិច្ចព្រមព្រៀងរវាងកម្មកររនិយោជិតជាមួយនិយោជក ចំនួន ៣ ច្បាប់
- វិញ្ញាបនបត្រពាណិជ្ជកម្ម/អាជីវកម្ម (ថតចម្លង) ចំនួន ៣ ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ថតចម្លង) ចំនួន ៣ ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ ច្បាប់

២-ការរៀបចំបញ្ជីរាយនាមកម្មកររនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ ច្បាប់ និងផ្ញើជា Soft Copy តាមទម្រង់ MS Excel មកកាន់ Email: suspension@nea.gov.kh ហើយត្រូវមានទិន្នន័យដូចខាងក្រោម៖

- ឈ្មោះកម្មកររនិយោជិត/ភេទ/ថ្ងៃខែឆ្នាំកំណើត/បម្រើការនៅផ្នែក
- លេខប័ណ្ណសមាជិកប.ស.ស/លេខរៀងក្នុងបញ្ជីកម្មកររនិយោជិតដែលបានធ្វើបច្ចុប្បន្នភាពមកក្រសួង
- លេខអត្តសញ្ញាណប័ណ្ណ
- លេខទូរស័ព្ទ (ផ្ទាល់ខ្លួន)
- ស្នាមមេដៃស្តាំ

៣-ការបោះត្រាក្រុមហ៊ុននៅគ្រប់ទំព័រនៃបញ្ជីរាយនាមកម្មកររនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ

៤-ការទទួលខុសត្រូវបង់ជូនកម្មកររនិយោជិតនូវប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាអាមេរិក ក្នុងមួយខែ ក្នុងករណីមិនបានផ្សព្វផ្សាយ និងមិនបានតម្រូវឱ្យកម្មកររនិយោជិតផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ដែលខ្លួនបានចងក្រងរួច និងផ្តិតស្នាមមេដៃបញ្ជាក់។

៥-ក្រុមហ៊ុនបានប្រាប់កម្មកររនិយោជិតឱ្យទិញលេខទូរស័ព្ទ (ករណីគ្មានលេខទូរស័ព្ទ) ហើយនឹងកាត់បញ្ជីឈ្មោះកម្មកររនិយោជិតទាំងឡាយណាដែលមិនមានលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទចេញពីបញ្ជីឈ្មោះកម្មកររនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ។

ខ្ញុំក្នុងនាមនិយោជក បានយល់និងឯកភាពគោរពតាមការណែនាំដូចមានខាងលើ នៅចំពោះមុខអធិការការងារ និងសូមប្តេជ្ញាចិត្តអនុវត្តតាមការណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសូមទទួលខុសត្រូវចំពោះមុខច្បាប់ លើការធានាអះអាងនេះ។

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣

តំណាងនិយោជក
ស្នាមមេដៃស្តាំ

លី សៀវមិញ

អធិការការងារ
ស្នាមមេដៃស្តាំ

ឡូញ ង៉ែត